ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីជូនព័ត៌មាន
# លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបលើកទី១៣ និងកិច្ចប្រជុំពាក់ព័ន្ធ
# រដ្ឋធានីណៃពីដោ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ារ
# ថ្ងៃទី២០ ដល់ ២១ ខែវិច្ឆិកា ឆ្នាំ២០១៧

-----------------

ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈប្រតិភូក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបលើកទី១៣ ក្រោមមូលបទ «**ការពង្រឹងភាពជាដៃគូដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព**» ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅរដ្ឋធានីណៃពីដោ សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ារ តបតាមការអញ្ជើញរបស់ **លោកជំទាវ អោង សាន ស៊ូជី** (Aung San Suu Kyi) ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ារ។

## ១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបលើកទី១៣៖

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ី-អឺរ៉ុបលើកទី១៣ បានប្រព្រឹត្តទៅដោយផ្តោតលើរបៀបវារៈសំខាន់ៗមានជាអាទិ៍ ការផ្សាភ្ជាប់រវាងសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ការបង្កើតភាពជាដៃគូអាស៊ី-អឺរ៉ុបដ៏ក្លៀវក្លានិងកាន់តែជិតស្និទ្ធ និងការផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់ និងអន្តរជាតិ។ បញ្ហាសន្តិសុខត្រូវបានលើកឡើងច្រើននៅក្នុងអង្គប្រជុំ ដូចជាវិបត្តិជនភៀសខ្លួនរ៉ូហ៊ីងយ៉ា បញ្ហានុយក្លេអ៊ែរកូរ៉េខាងជើង និងការប្រយុទ្ធប្រឆាំងភេរវកម្ម និងអំពើហឹង្សាជ្រុលនិយម។ បញ្ហាសន្តិសុខដែនសមុទ្រ ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត ការប្រែប្រួលអាកាសធាតុ សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ និងទេសន្តរប្រវេសន៍ ក៏ត្រូវបានអង្គប្រជុំលើកឡើងផងដែរ។

ក្រៅពីការប្តេជ្ញាសម្រេចឲ្យបាននូវគោលដៅនៃរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ អង្គប្រជុំបានពិភាក្សាផុលផុសអំពី «ការពង្រឹងការតភ្ជាប់អាស៊ី-អឺរ៉ុប» ដែលសំដៅជំរុញកំណើនសេដ្ឋកិច្ច និងធ្វើឲ្យប្រទេសនិងប្រជាជនអាស៊ី-អឺរ៉ុបកាន់តែខិតជិតគ្នាតាមរយៈការលើកកំពស់ស្មារតីសន្តិភាព ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក។ អង្គប្រជុំ

បានអនុម័តលើ «និយមន័យអំពីការតភ្ជាប់អាស៊ី-អឺរ៉ុប» និងកំណត់នូវវិសាលភាព និងកាលវិភាគរបស់ក្រុមការងារស្វែងរកមាគ៌ាសំរាប់ការតភ្ជាប់អាស៊ី-អឺរ៉ុប ដើម្បីលើកអនុសាសន៍អំពីវិស័យអាទិភាពនៃការតភ្ជាប់អាស៊ី-អឺរ៉ុប ដាក់ជូនកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៤ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងព្រុចសែល ប្រទេសប៊ែលហ្សិក ក្នុងឆ្នាំ២០១៨ ខាងមុខ។

ក្នុងឱកាសកិច្ចប្រជុំនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានធ្វើបទអន្តរាគមន៍លើប្រធានបទអំពីការផ្សាភ្ជាប់សន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព ដោយបានសង្កត់ធ្ងន់អំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលតាមរយៈ «នយោបាយឈ្នះ-ឈ្នះ» របស់**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ក្នុងការបង្កើតនិងការពារសន្តិភាព និងការស្តារប្រទេសឡើងវិញដោយប្រកាន់យកការប្តេជ្ញាដ៏ច្បាស់លាស់ ដើម្បីសម្រេចនូវការអភិវឌ្ឍប្រកបដោយចីរភាព។ ជាក់ស្តែង ការសម្រេចមុនកាលកំណត់នូវគោលដៅកាត់បន្ថយអត្រាភាពក្រីក្រមកត្រឹម១៩,៥%នៅឆ្នាំ២០១៥ កំណើនជាមធ្យមជាង៧%ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ បានធ្វើឲ្យកម្ពុជាចាកចេញពីប្រទេសដែលមានចំណូលកម្រិតទាប មកប្រទេសមានចំណូលមធ្យមកម្រិតទាប។ ការប្រកួតប្រជែងដណ្តើមយកឥទ្ធិពលក្នុងតំបន់និងសកលលោក ការជ្រៀតជ្រែកដោយផ្ទាល់ពីបរទេស អាចនាំឲ្យអន្តរាយដល់សន្តិភាពដែលយើងសម្រេចបានដោយលំបាក។

**២. <u>ជំនួបទ្វេភាគី (ថ្ងៃទី២០-២១ ខែវិច្ឆិកា ឆ្នាំ២០១៧)</u>៖**

ក្នុងអំឡុងពេលស្នាក់នៅប្រទេសមីយ៉ាន់ម៉ារ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវ អោង សាន ស៊ូជី (Aung San Suu Kyi) ទីប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីការបរទេសមីយ៉ាន់ម៉ារ ឯកឧត្តម វ៉ាង យី (Wang Yi) រដ្ឋមន្ត្រីការបរទេសចិន ឯកឧត្តម ហ្សង់អ៊ីវ ឡឺឌ្រីយ៉ង់ (Jean-Yves Le Drian) រដ្ឋមន្ត្រីអឺរ៉ុបនិងកិច្ចការបរទេសបារាំង លោកជំទាវ ហ្វេដេរីកា ម៉ូហ្គេរីនី (Federica Mogherini) អនុប្រធានគណៈកម្មការអឺរ៉ុបនិងជាតំណាងជាន់ខ្ពស់សហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេសនិងគោលនយោបាយសន្តិសុខ ឯកឧត្តម ភីធ័រ ហ្សីជីតូ (Peter SZIJIRTO) រដ្ឋមន្ត្រីការបរទេស និងពាណិជ្ជកម្មហុងគ្រី ឯកឧត្តម កាហ្ស៊ុយុគី ណាកានេ (Kazuyuki NAKANE) អនុរដ្ឋមន្ត្រីការបរទេសជប៉ុន និងឯកឧត្តម ម៉ាក ហ្វៀល (Mark Field) អនុរដ្ឋមន្ត្រីការបរទេសអង់គ្លេស ព្រមទាំងបានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីការបរទេសមួយចំនួននៃប្រទេសអាស៊ាន អនុរដ្ឋមន្ត្រីការបរទេសរុស្ស៊ី និងអនុរដ្ឋមន្ត្រីការបរទេសរ៉ូម៉ានីផងដែរ ដើម្បីឆ្លៀតពន្យល់ពីស្ថានការណ៍កម្ពុជា។

នៅក្នុងជំនួបជាមួយ**លោកជំទាវ អោង សាន ស៊ូជី ឯកឧត្តមទេសរដ្ឋមន្ត្រី** បានចុះហត្ថលេខាជាមួយអនុរដ្ឋមន្ត្រីការបរទេសមីយ៉ាន់ម៉ារ លើអនុស្សារណៈយោគយល់គ្នាស្តីកិច្ចពិគ្រោះយោបល់នយោបាយរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧